ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
......................./................ ../..............................
ម៉ោង (Time/Heure):..............................................
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: ..............................................

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ពុធ ទី ០៦ ខែ មេសា ឆ្នាំ ២០១៦

**សវនាការលើអង្គសេចក្តី - ថ្ងៃ ៣៩៦**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង Evelyn CAMPOS SANCHEZ

| **កំណត់ហេតុអ្នកចូលរួម** |
| --- |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN , ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង លាង |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លើវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ហុង គីមសួន, លោក ឡោ ជុនធី, លោកស្រី ជេត វណ្ណលី,លោក វ៉ែន ពៅ, លោកស្រី ស៊ីន សុវ៉ន |

| |
|---|
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ លោក សុះ កំរី (2-TCW-827) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, កញ្ញា សុក សុភ័គមណីកា, លោក មៀច សុវណ្ណា, កញ្ញា ពេជ ចរិយា, កញ្ញា ស្រី ណាក់ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៦.០៤ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៥ | បញ្ចប់ម៉ោង៖ ១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤២ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ៣៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៣ | ០៩.០៤ |
| ការតាំងសំណួរទៅកាន់សាក្សី សុះ កំរី (2-TCW-827) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦<br>០៩.១៤<br>១០.៥៥<br>១០.៥៩<br>១៥.១៣ | ០៩.១៤<br>១០.៥៥<br>១០.៥៩<br>១៥.១៣<br>១៦.០២ |
| សេចក្តីបញ្ជាក់ទៅលើវិធាន ២៤(១) នៃវិធានផ្ទៃក្នុង | មេធាវីការពារក្តីលោក នួន ជា<br>អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ០៩.៣២<br>០៩.៣២<br>០៩.៣៧ | ០៩.៤០<br>០៩.៣៦<br>០៩.៣៨ |
| សំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំឱ្យទទួលយក | មេធាវីការពារក្តី ខៀវ សំផន | ១១.១៣ | ១១.១៨ |

| ឯកសារលេខ D175/3.43 ជាភស្តុតាង | | | |
|---|---|---|---|

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅកាន់សាក្សី សុះ កំរី (2-TCW-827)**

អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី សុះ កំរី (2-TCW-827)។

**សេចក្តីបញ្ជាក់លើវិធាន ២៤(១) នៃវិធានផ្ទៃក្នុង**

មេធាវីការពារក្តី នួន ជា បានសួរបញ្ជាក់អំពីមូលហេតុដែលថាសាក្សីមិនបានធ្វើសម្បថមុនពេលដែលសាក្សីចូលមកផ្តល់សក្ខីកម្ម ហើយថាតើនេះមានន័យថាសាក្សីរូបនេះផ្តល់សក្ខីកម្មដោយមិនធ្វើសម្បថ ឬ យ៉ាងណា។ អង្គជំនុំជម្រះបានបញ្ជាក់ថាវិធាន ២៤(១) នៃវិធានផ្ទៃក្នុង គឺមានជម្រើសពីរសម្រាប់សាក្សីក្នុងការធ្វើសម្បថ៖ សាក្សីធ្វើសម្បថតាមជំនឿសាសនា ហើយនិង/ឬ សាក្សីអាចប្តេជ្ញាថាគាត់និយាយតែការណ៍ណាដែលពិត។ អង្គជំនុំជម្រះបញ្ជាក់ថា តាមកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ សាក្សីរូបនេះមិនបានធ្វើសម្បថចំពោះមុខអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស នោះទេ ដោយសារតាមជំនឿសាសនារបស់សាក្សី ប្រសិនបើគាត់ជាមេសាសនា គាត់មិនត្រូវធ្វើសម្បថនោះទេមុននឹងនិយាយ។ ប្រធានអង្គជំនុំជម្រះបានប្រាប់ទៅភាគីពាក់ព័ន្ធថា ចៅក្រមបានពិភាក្សារួចហើយកាលពីម្សិលមិញទៅលើបញ្ហានេះ ហើយសម្រេចយកជម្រើសទី ២ ដែលមានចែងក្នុងវិធាន ២៤(១) នៃវិធានផ្ទៃក្នុង ។

**សំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំឱ្យទទួលយកឯកសារ D175/3.43 ជាភស្តុតាង**

មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថាគួរត្រូវមានសំណើអនុលោមតាមវិធាន ៨៧(៤)

នៃវិធានផ្ទៃក្នុង ស្នើសុំឱ្យទទួលយកឯកសារ D175/3.43 ជាភស្តុតាង បន្ទាប់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រើប្រាស់ឯកសារនេះក្នុងការតាំងសំណួរទៅសាក្សី។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួននឹងដាក់សំណើសុំ។ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារនោះ ដោយសារតែមិនមានភាគីណាជំទាស់ទៅលើឯកសារនោះទេ។

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9750 | D175/3.43 | 00230600-00230614; 01222001-01222011; 01222012-01222023 | Confession of Soh Komry | P | 00230610<br>00230603 | 01222008<br>01222005<br>01222004 | 01222019<br>01222016 |
| E3/5216 | D125/126 | 00223890-00223895; 00225494-00225499; 00234567-00234572 | Written Record of Interview of SOH Kamrei | P | 00223891<br>00223893<br>00223894<br>00223892 | 00225495<br>00223897<br>00225498<br>00225496 | 00234568<br>00234570-00234571<br>00234569 |
| E3/9382 | D108/43/11 | 00169557-00169558 | Annex 11: Radio comment on National effort against Vietnamese dated 06 January 1978 | P | - | - | - |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/7690 | D125/126.1 | 00223896; 00223897-00223899; 00485382 | Annex1: Extract of "The Cham Rebellion, Survivors'Stories | P | 00223896 | 00223899 | 00485382 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | from the Villages", Ysa Osman, Documentation series No. 9, DC-Cam, 2006, page 116 (English) | | | | |
| E3/9701 | E367/4.1.4 | 01206398-01206401; 01199557-01199558 - | Attachment 4: YSA Osman, 'How many Cham killed important genocide evidence', Phnom Penh Post, 10 March 2006 | P | 01206400-01206401 | 01191557 | - |
| E3/2653 | D196.2 | 00904196-00904430; 00219050-00219245; 00943973-00943985 | Annex B 0001: YSA Osman, "The Cham Rebellion: Survivors' Stories from the Village", DC-Cam, 2006 | P | 00904362 | 00219177 | 00943975 |
| E3/9517 | E319/19.3.86 | 00982228-00982236; 00987774-00987786; - | Written Record of Interview of BAN Siek | C | 00982231 | 00987778 | - |
| E3/9516 | E319/19.3.13 | 00989336-00989354; 01075201-01075219; 01118098-01118111 | Written Record of Interview of ORM Huon | C | 00800955 | 00841966 | 00841971-00841972 |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៤)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក

| |
|---|
| នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៦។ (១៦.០៣) |

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ី[illegible] E[illegible]n CAMPOS SANCHEZ